# ពិធីបុណ្យនិងការរំឭកវិញ្ញាណខ័ណ្ឌ៖
# រូបថតចេញពីមន្ទីរស–21
# ប្រទេសកម្ពុជា

រូបថតរបស់មនុស្សម្នាក់ៗនៅក្នុងការតាំងពិពណ៌នេះ មានចំនួន 104 រូប សម្រាប់ តំណាងឲ្យជនរងគ្រោះក្នុងរបបខ្មែរក្រហម ដែលបានគ្រប់គ្រងប្រទេសកម្ពុជា ចាប់ពី ថ្ងៃទី 17 ខែមេសា ឆ្នាំ1975 រហូតដល់ថ្ងៃទី7 ខែមករា ឆ្នាំ1979 ដោយបានធ្វើឲ្យ មនុស្ស ស្លាប់អស់ប្រហែល 2 លាននាក់ ។ ការបាត់បង់ជីវិតដ៏ច្រើនសន្ធឹកសន្ធាប់នេះ មាន ចំនួនប្រហែលជាមួយភាគបួន នៃចំនួនសរុបរបស់ប្រជាជនកម្ពុជា ដែលគឺជាលទ្ធផល នៃចំនួនក្នុងការកាប់សម្លាប់លាក់កំបាំង នៅតាមទីលានប្រហារជីវិតច្រើនជាង 19,000 កន្លែង ហើយក៏ជាផ្លែផ្កានៃគោលនយោបាយរបស់ខ្មែរក្រហម ដែលនាំឲ្យមាន មនុស្ស រាប់រយពាន់នាក់ បានស្លាប់បាត់បង់ជីវិតពីការធ្វើការធ្ងន់លើសកម្រិត ការអត់ឃ្លាន និងជម្ងឺផ្សេងៗ ។

រូបថតរបស់មនុស្សប្រុស ស្រី និងកុមារដែលអ្នកនឹងបានឃើញ ពួកគេសុទ្ធ តែជាអ្នក ដែលមានវាសនាដ៏គួរឲ្យរន្ធត់ ។ ដោយពួកគេទាំងអស់នោះត្រូវទទួលរងនូវការចោទ ប្រកាន់ថាជាជនក្បត់ជាតិ ពួកគេត្រូវបានចាប់ដាក់គុកនៅមន្ទីរស–21 ដ៏គួរឲ្យខ្លាច ដោយពួកគេត្រូវរងនូវទណ្ឌកម្មរួចត្រូវបានអង្គការកម្ទេចចោលយ៉ាងព្រៃផ្សៃបំផុត ក្នុងស្មារតីសំអាតប្រទេស ដោយការកំចាត់សត្រូវនយោបាយរបស់ខ្លួនចោលឲ្យអស់ ។ ពួកគេទាំងនេះ ក៏ជាអ្នកដែលមានវាសនាបច្ឆាមរណៈរួមគ្នា ដោយរូបថត របស់ពួកគេ ទាំងអស់ ជាសាក្សីចំពោះអំពើយង់ឃ្នងដែលបង្ករឡើងដោយពួកខ្មែរក្រហម ។

រូបថតទាំងនេះ ត្រូវបានដាក់បង្ហាញទីនេះ ដើម្បីធ្វើជាឯកសាររបស់ជនរងគ្រោះម្នាក់ៗ ដែលត្រូវបានកាត់ទោសប្រហារជីវិត ។ ទោះជាយ៉ាងណាក៏ដោយ រូបថតរបស់ពួកគេ ទាំងនោះ ត្រូវបានរៀបចំជាលក្ខណៈបែបនេះ ។ ជាឯកសារ និងជាវិចិត្ររូប រូបថត ទាំងនេះ បង្ហាញឲ្យឃើញយ៉ាងជ្រាលជ្រៅ នូវការបាត់បង់ដ៏គួរឲ្យខ្លោចផ្សារ ដែល បណ្តាលមកពីហេតុការណ៍ ដែលត្រូវបានមនុស្សគ្រប់គ្នាស្គាល់ថាជា "ការប្រល័យពូជសាសន៍កម្ពុជា" ។ ការតាំងពិពណ៌នេះ គឺជាការធ្វើអភិវន្ទនាការចំពោះជនរងគ្រោះ ក្នុងរបបខ្មែរក្រហមទាំងអស់ ដែលមួយភាគធំនៃអ្នកទាំងនោះ ត្រូវបានកំចាត់ចោលដោយមិនមានស្លាកស្នាមនៅក្នុងទីវាលពិឃាតរបស់កម្ពុជាឡើយ ហើយក៏សម្រាប់ជន រងគ្រោះដែលមិនមានរូបថត ដើម្បីបញ្ជាក់ពីការស្លាប់ របស់ពួកគេផងដែរ ។ រូបថត របស់ជនរងគ្រោះ ដែលអ្នកនឹងបានឃើញមិនមែនគ្រាន់តែបង្កើតនូវករណីយកិច្ចដែល ត្រូវចងចាំ ព្រមទាំងអ្វីដែលស្ថិតនៅជាលក្ខណៈស្ងប់ស្ងាត់ទេ គឺជាការអង្វរករដ៏ខ្លាំង ដើម្បីទាមទាររកយុត្តិធម៌ ។ ពួកគេធ្វើឲ្យយើងនឹកឃើញដល់សមត្ថភាពរបស់មនុស្ស ជាតិលើទុជិន ភាពចំពោះមនុស្សដូចគ្នា ដែលយើងទាំងអស់គ្នា ជានិច្ចកាលត្រូវតែមាន ការប្រយ័ត្នប្រយែងជាប់ជានិច្ច ។

# ទស្សនវិស័យចំពោះការតាំងពិពណ៌នេះ

*ពិធីបុណ្យ និងការរំឭកវិញ្ញាណខ័ណ្ឌ* ដើម្បីជាកិត្តិយស និងការគោរពចំពោះការចង ចាំដល់ជនកម្ពុជាប្រហែលជា 2 លាននាក់ដែលត្រូវបានសម្លាប់នៅក្នុងប្រទេសកម្ពុជា ក្រោមរបបខ្មែរក្រហម ។ អំពើឃោរឃៅដែលបានកើតឡើង ក្នុងរវាងឆ្នាំ 1975 ដល់ឆ្នាំ 1979 មិនត្រូវបានជនកាណាជាមួយចំនួនធំបានដឹងឡើយ ដោយសារថាប្រទេស កម្ពុជា ត្រូវបានហ៊ុំព័ទ្ធផ្តាច់ទំនាក់ទំនងពីពិភពលោក នៅក្នុងសម័យនោះ ហើយរឿងរ៉ាវទាំងនេះ ត្រូវបានរាយការណ៍យ៉ាងតិចតួចបំផុត នៅក្នុងវិស័យព័ត៌មានរបស់លោកខាង លិច ។ នេះគឺជាពេលដ៏សមរម្យបំផុត ដើម្បីនាំគ្នារំឭកអំពីការប្រល័យពូជសាសន៍ កម្ពុជា ខណៈពេលដែលការកាត់ទោសមេដឹកនាំជាន់ខ្ពស់របស់របបខ្មែរក្រហម ដែល ត្រូវពន្យារពេលដ៏យូរមួយទីបំផុតកំពុងតែដំណើរការហើយ ។ ការដាក់បង្ហាញនេះ ផ្តល់នូវបរិបទមួយ ដែលជួយឲ្យយើងយល់បានកាន់តែប្រសើរ នូវដំណើរការប្រវត្តិសាស្ត្រទាំងនេះ ។

យើងសង្ឃឹមថា ក្របខ័ណ្ឌប្រវត្តិសាស្ត្រ ដែលផ្តល់ជូនដោយ *ពិធីបុណ្យ និងការរំឭក វិញ្ញាណខ័ណ្ឌ* នឹងជួយលោកអ្នកឲ្យអាចយល់បាននូវភាពស្មុគ្រស្មាញនៃរូបថតរបស់ អ្នកទោសមន្ទីរស–21 ។ ពេលដែលអ្នកបាន ឃើញរូបថតដ៏មានឥទ្ធិពលទាំងនេះ ចូរ ចាត់ទុកថាវាគឺជាភស្តុតាងនៃបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ហើយគិតអំពីអត្តសញ្ញាណ របស់ពួកគេ ព្រមទាំងភាពតែលតោលរបស់ជនរងគ្រោះទាំងនោះ ។ ការឆ្លើយតបជាលក្ខណៈបុគ្គលរបស់អ្នក អាចជាភាពរំជួលចិត្ត ក៏ដូចជាភាពហ្មត់ហ្មង និងគំនិត ប្រាជ្ញា ផងដែរ ។

ការតាំងពិពណ៌នេះផ្តល់នូវឱកាសដើម្បីឆ្លុះបញ្ចាំងលើបញ្ហាពិបាកផ្នែកសីលធម៌ និង បញ្ហានយោបាយ ដែលជាញយៗមិនត្រូវបានដោះស្រាយ នៅក្នុងសារមន្ទីរ ដូចជាកេរ្តិ៍ ដំណែលក្រោយរបបអាណានិគម របបចក្រពត្តិនិយម ជាតិនិយម អច្ឆន្តិកភាពផ្ទៃក មនោគមវិជ្ជា គណនេយ្យភាព និងយុត្តិធម៌ ។ បញ្ហាដដែលៗមួយចំនួនធំទាំងនេះបាន ចូលរួមក្នុងការបង្កើតឲ្យមានអំពើឃោរឃៅក្នុងថ្ងៃនេះ ក្នុងផ្នែកដទៃទៀតនៃដម្លោះ ។ យើងខ្ញុំសង្ឃឹមថា ការតាំងពិពណ៌នេះនឹងជម្រុញឲ្យមានការចូលរួមកាន់តែ ច្រើននៅ ក្នុងអង្គការដែលលះបង់ដើម្បីការពារសិទ្ធិមនុស្សនៅជុំវិញពិភពលោក ។

# ការកកើតខ្មែរក្រហម

## ប្រវត្តិដើម

ចាប់តាំងពីសតវត្សរ៍ទី 9 ដល់សតវត្សរ៍ទី 15 ប្រទេសកម្ពុជាគឺជាចំណុចកណ្តាលនៃ អាណាចក្រខ្មែរ ។ ប្រាសាទអង្គរវត្ត និងប្រាសាទអង្គរធំដ៏អស្ចារ្យរបស់ខ្មែរ នាពេល បច្ចុប្បន្ន ស្ថិតក្នុងចំណោមបុរាណដ្ឋានក្នុងលោកដែលគេនិយមចូលមកទស្សនាច្រើន បំផុត ។ ការបាត់បង់ទឹកដីទៅឲ្យប្រទេសថៃឡង់ដ៍ និងប្រទេសវៀតណាម ក្នុងអំឡុង សតវត្សរ៍ទី 16 – សតវត្សរ៍ទី 19 នាំឲ្យក្នុងឆ្នាំ1863 ព្រះបាទនរោត្តមធ្វើការសម្រេចព្រះទ័យ ចុះកិច្ចព្រមព្រៀងជាមួយនឹងប្រទេសបារាំង ដើម្បីបង្កើតជារាជការអាណាព្យា បាល ។ ការព្រមព្រៀងនេះ កើតឡើងក្នុងយុគដែលប្រទេសបារាំងដើរដាក់អាណានិគមក្នុងលោក ដែលស្ថិតនៅរហូតដល់ឆ្នាំ 1953 ។

## ដើមកំណើត ៖ អាណានិគមនិយម សង្គ្រាម រដ្ឋប្រហារ

ឫសគល់នៃការឡើងកាន់អំណាចរបស់ខ្មែរក្រហម ស្ថិតក្នុងការឆ្លើយតបរបស់កម្ពុជា ចំពោះរបបអាណានិគមបារាំងដែលមានរយៈពេល 90 ឆ្នាំ ដែលសកម្មភាពទាំងនោះ បង្កឲ្យមានចលនាជាតិនិយម និងចលនាកុម្មុនីស្តនិយម ។ សង្គ្រាមផ្តាច់ផ្តិលចំនួនបួន ក្នុងរយៈពេលបួនទសវត្សរ៍ជាកត្តានាំមុខដែលជួយឲ្យខ្មែរក្រហមអាចចាប់យក អំណាច និងដើរតួជាកត្តាលិករបស់ក្រុមនេះផងដែរ ។ ពេលដែលកងទ័ពជប៉ុន កាន់កាប់ប្រទេសកម្ពុជា ក្នុងអំឡុង **សង្គ្រាមលោកលើកទី II** (1939–1945) ពួកគេបាន រំលោយរដ្ឋបាលអាណានិគម បារាំងហើយជម្រុញឲ្យកម្ពុជាមានឯករាជ្យ ។ នៅថ្ងៃទី9 ខែមីនា ឆ្នាំ1945 ព្រះបាទនរោត្តម សីហនុ បានប្រកាសឯករាជ្យជាតិ ។ តែក្នុងពេល ដែលប្រទេសជប៉ុនបានចុះចាញ់សង្គ្រាមជាផ្លូវការ នាខែសីហា ឆ្នាំ 1945 ប្រទេស បារាំង បានមានលទ្ធភាពក្នុងការបង្កើតរដ្ឋបាលអាណានិគមរបស់ខ្លួនឡើងវិញនៅ ក្នុងប្រទេសឥណ្ឌូចិន ដោយរួមទាំងកម្ពុជា ។ ក្នុងអំឡុងពេល **សង្គ្រាមឥណ្ឌូចិនលើក ទីមួយ** (1946–1954) ក្នុងប្រទេសវៀតណាម ដែលជាប្រទេសភូមិផងរបងជាមួយ ពេលនោះក្រុមកុម្មុយនិស្ត កម្ពុជាក៏បានបង្កើតឡើង ហើយបានធ្វើសម្ព័ន្ធមិត្តជាមួយ នឹងកុម្មុយនិស្តវៀតណាម ក្នុងការតស៊ូរួមគ្នាប្រឆាំងនឹងបារាំង ។ និស្សិតដែលជាអ្នក ជាតិនិយម ដូចជាប៉ុល ពត និងអ្នកដទៃដែលជាអនាគតមេដឹកនាំរបបខ្មែរក្រហម ក៏បានក្លាយជាជនកុម្មុយនិស្ត ក្នុងពេលដែលពួកគេកំពុងតែសិក្សានៅបរទេស ហើយ ក៏ត្រឡប់កកម្ពុជាវិញ ដើម្បីប្តេជ្ញាធ្វើឲ្យលូតលាស់នូវចលនាដែលកំពុងលាក់ខ្លួន ។ ខ្មែរក្រហមបានបង្កើតក្រុមទ័ពព្រៃតូចមួយ ដែលមិនមានអាវុធគ្រប់គ្រាន់ សម្រាប់ ប្រយុទ្ធប្រឆាំងជាមួយនឹងរដ្ឋាភិបាល ។ ក្នុងឆ្នាំ 1970 ពេលដែលប្រមុខរដ្ឋស្ថិតក្នុង តំណែងយូរអង្វែង គឺព្រះអង្គម្ចាស់សីហនុ ត្រូវបានទម្លាក់ពីតំណែងដោយរដ្ឋប្រហារ ដឹកនាំដោយឧត្តមសេនីយលន់ ណុល ដែលមានអាមេរិកាំងនៅពីក្រោយខ្នង ហើយ **សង្គ្រាមក្នុងស្រុកកម្ពុជា** (1970–1975) ក៏បានកើតឡើង ។ រដ្ឋការលោកលន់ ណុល ត្រូវបានគេមើលឃើញថាជារដ្ឋបាលពុករលួយ ហើយបានបាត់បង់ប្រជាប្រិយភាពយ៉ាងច្រើន ហើយប្រជាជនកម្ពុជាជាច្រើនបានចូលរួមជាមួយខ្មែរក្រហម ដើម្បីជួយនាំអំណាចមកប្រគល់ឲ្យព្រះអង្គម្ចាស់សីហនុ វិញ ។

## ខ្មែរក្រហមចាប់យកអំណាច

សង្គ្រាមឥណ្ឌូចិនទីពីរ ដែលត្រូវបានគេស្គាល់ផងដែរថាជា **សង្គ្រាមវៀតណាម** ( 1955 – 1975 ) បានរាលដាលចូលមកក្នុងដែនដីកម្ពុជាកាន់តែជ្រៅទៅៗក្នុងសម័យសង្គ្រាម ក្នុងស្រុកកម្ពុជា ដែលបានបង្កឲ្យមានជម្លោះនយោបាយ បន្ថែមមួយកម្រិតទៀត ។ ការទម្លាក់គ្រាប់បែកពីអាកាសយ៉ាងធ្ងន់ធ្ងរបស់អាមេរិក ទៅលើកងទ័ពវៀតកុង និង កងទ័ពវៀតណាម ខាងជើង ព្រមទាំងផ្លូវដឹកជញ្ជូននៅក្នុងប្រទេសកម្ពុជា បាន សម្លាប់ជីវិតជនស៊ីវិលកម្ពុជាអស់ជាច្រើនពាន់នាក់ ។ ការបំផ្លិចបំផ្លាញបណ្តាលពី ការទម្លាក់គ្រាប់បែកទាំងនេះ កាន់តែជុតកំដៅលើអារម្មណ៍ប្រឆាំងនឹងរដ្ឋាភិបាល ដែលជាការបំផុសឲ្យប្រជាជនប្រុសស្រីរាប់ពាន់នាក់ ចូលរួមជាមួយនឹងក្រុមខ្មែរ ក្រហម ។ ដល់ឆ្នាំ 1973 ខ្មែរក្រហមបានក្លាយជាកម្លាំងមួយដែលមានទាហានច្រើន ជាង 40,000 នាក់ ។

ដោយបានជំនួយពីវៀតណាមខាងជើង និងប្រទេសចិន និងដឹកនាំដោយ ប៉ុល ពត ពួកខ្មែរក្រហមបានចាប់យកអំណាចនៅក្នុងប្រទេសកម្ពុជានៅថ្ងៃទី17 ខែមេសា ឆ្នាំ 1975 ។ ក្នុងរវាងតែពីរបីម៉ោងដែលពួកគេបានចូលមកដល់ទីក្រុងភ្នំពេញ ពួកគេបាន ជន្លាសដោយបង្ខំនូវប្រជាជនចំនួន 2 លាននាក់ចេញពីក្រុង ។ ក្រោយមកបន្តិច ពួក គេបានចាប់ផ្តើមយុត្តាធិការ ដើម្បីបំបាត់សត្រូវនយោបាយរបស់ខ្លួន ដោយការ សម្លាប់ទាហានមន្ត្រីយោធា និងមន្ត្រីរដ្ឋការស៊ីវិលនៃរបបលន់ ណុល ជាក្រុមៗ ។ ការដឹកនាំប្រទេសចំនួនបួនឆ្នាំ ប្រកបដោយការភ័យខ្លាច របស់ខ្មែរក្រហមបានចាប់ផ្តើម ។

## ការទម្លាក់គ្រាប់បែកពីអាកាសក្នុងប្រទេសកម្ពុជា

ចាប់ពីខែតុលា ឆ្នាំ1965 ដល់ខែសីហា ឆ្នាំ1973 សហរដ្ឋអាមេរិក បានទម្លាក់គ្រាប់បែក សរុបទាំងអស់ចំនួន 2,756,941 តោន នៅភូមិភាគបូពាក្នុងអំឡុងពេលការវាយ ប្រហារតាមអាកាសចំនួន 230,516 លើទីតាំងចំនួន 113,716 កន្លែង ។ កងទ័ពអាកាសសហរដ្ឋអាមេរិក បានទម្លាក់គ្រាប់បែកជាច្រើនតោននៅតំបន់បូពាកម្ពុជា ចាប់ពីឆ្នាំ1965 ដល់ឆ្នាំ1973 គឺមានចំនួន ច្រើនជាងកងកម្លាំងសម្ព័ន្ធមិត្តទម្លាក់ទាំងអស់ ក្នុងសង្គ្រាមលោកលើកទីពីរទៅទៀត ។

#### ចម្រៀងជាតិរបស់កម្ពុជាប្រជាធិបតេយ្យ ៖ ភាពរុងរឿងថ្ងៃ17 មេសា

ឈាមក្រហមប្រាល ស្រោចសព្វក្រុងវាល កម្ពុជាមាតុភូមិ! ឈាមកម្មករ កសិករដ៏ ឧត្តម! ឈាមយុទ្ធជន យុទ្ធនារីបដិវត្ត! ។

ឈាមប្រែក្លាយជាកំហឹងខ្លាំងក្លា តស៊ូមោះមុត! 17មេសា ក្រោមទង់បដិវត្ត! ឈាម រំដោះអំពីភាពខ្ញុំគេ! ។

ជយោ! ជយោ! 17មេសាជោគជ័យ! មហាអស្ចារ្យ មានន័យ ធំជាង លើសសម័យអង្គរ! យើងរួបរួមគ្នាកសាងកម្ពុជា និងសង្គមថ្មីបវរប្រជាធិបតេយ្យ សមភាព និងយុត្តិធម៌ ។ តាមមាគ៌ាម្ចាស់ការ ឯករាជ្យរឹងមាំ ។

ប្តេជ្ញាដាច់ខាតការពារមាតុភូមិ ទឹកដីឧត្តម បដិវត្តដ៏រុងរឿង ។

ជយោ! ជយោ! ជយោកម្ពុជាថ្មី ប្រជាធិបតេយ្យ សម្បូរថ្កុំថ្កើង! ប្តេជ្ញា ជ្រោងគ្រវីទង់ ក្រហមបដិវត្តក្រហមខ្ពស់ឡើង
សាងមាតុភូមិយើងឲ្យចម្រើនលោតផ្លោះ មហារុង រឿង មហាអស្ចារ្យ!

# មនោគមវិជ្ជាខ្មែរក្រហម

**កសិករក្សេមក្សាន្តនិយម – ក្នុងទ្រឹស្តី**

ខ្មែរក្រហម ដែលមានឈ្មោះជាផ្លូវការបក្សកុម្មុយនិស្តកម្ពុជា (CPK) ត្រូវការបំផ្លែង សង្គមទាំងស្រុង ដោយសំអាងលើការបកស្រាយបែប រ៉ាឌីកាល់ នៃមនោគមវិជ្ជាម៉ៅ និយម និងម៉ាកឡេនីននិយម ។ រដ្ឋថ្មី ដែលមានឈ្មោះថាកម្ពុជាប្រជាធិបតេយ្យ (DK) នឹងជារដ្ឋសមភាព កសិករក្សេមក្សាន្ត ដែលជាកន្លែងមួយមិនមានអ្នកក្រ និងអ្នកមាន ឡើយ ហើយក៏គ្មានការកេញប្រវ័ញ្ច ឬពុករលួយដែរ ។ មូលដ្ឋានសេដ្ឋកិច្ច របស់ DK គឺកសិកម្ម ជាចម្បងសំអាងលើការប្រមូលផលស្រូវ  ។ សកម្មភាពដំបូងរបស់ពួកខ្មែរ ក្រហម ក្រោយពេលខ្លួនបានកាន់កាប់អំណាច គឺត្រូវកុំឲ្យមានមនុស្សរស់ នៅតាម ទី ក្រុង ហើយដើម្បីប្រមូលកម្លាំងទាំងនេះសម្រាប់ធ្វើការក្នុងគម្រោងកសិកម្មជនបទ ។

ពួកខ្មែរក្រហមបានដកហូតកម្មសិទ្ធិផ្ទាល់ខ្លួនទាំងអស់ លុបបំបាត់លុយ សាលារៀន មន្ទីរពេទ្យ និងតុលាការច្បាប់ ព្រមទាំងហាមមិនឲ្យធ្វើកិច្ចវត្ត សាសនាទៀតផង ។ គេរឹតបន្តឹងលើជីវិតគ្រួសារ និងសេរីភាពដើរហើរ ។ កុមារៗ ត្រូវបានគេបំបែកចេញ ពីគ្រួសាររបស់ខ្លួន ដោយការបញ្ជូនឲ្យទៅ ធ្វើការ ឬចូលបម្រើកងទ័ព ។ សិទ្ធិបុគ្គល ត្រូវ បានបំបាត់ទាំងអស់ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនកម្ពុជា ត្រូវ បានគេរំពឹងថា ត្រូវរស់ នៅដោយស្តាប់បង្គាប់ទាំងស្រុងចំពោះ "អង្គការ" – ក្រុមដឹកនាំបដិវត្ត ។

"ដើម្បីជីកស្មៅឲ្យអស់ គេត្រូវជីកវាទាំងឫស ។"
– ពាក្យស្លោករបស់ខ្មែរក្រហម

"ការសិក្សាមិនសំខាន់ឡើយ ។ អ្វីដែលសំខាន់គឺធ្វើការ និងបដិវត្ត ។"
– ពាក្យស្លោករបស់ខ្មែរក្រហម
"អ្នកតវ៉ាគឺជាសត្រូវ អ្នកដែលប្រឆាំងគឺជាខ្មោច ។"
– ពាក្យស្លោកខ្មែរក្រហម

"បំណោះដែលមាននៅក្នុងខួរក្បាលអ្នក គំនិតរបស់អ្នក ជាទ្រព្យសម្បត្តិផ្លូវចិត្តឯកជន ផងដែរ.... ប្រសិនបើអ្នកអាចបំផ្លាញសម្ភារៈទាំងអស់ ព្រមទាំងទ្រព្យសម្បត្តិផ្លូវចិត្ត ឯកជន... មនុស្សទាំងអស់នឹងស្មើភាពគ្នា ។"
– ខៀវ សំផន ថ្នាក់ដឹកនាំមួយរូបក្នុងរបបខ្មែរក្រហម

"អ្នកត្រូវបេះតាមដានគ្នាទៅវិញទៅមក ។ រាយការណ៍អ្វីៗគ្រប់យ៉ាងជូន អង្គការ [ក្រុមដឹកនាំបដិវត្ត] ។"
– ពាក្យស្លោកខ្មែរក្រហម

"វាប្រសើរក្នុងការចាប់មនុស្សដបនាក់ខុស ជាជាងលែងខ្មាំងមួយនាក់ឲ្យរួចខ្លួន ។"
– ពាក្យស្លោកខ្មែរក្រហម

"ទុកមិនចំណេញ ដកចេញមិនខាត ។"
– ពាក្យស្លោកខ្មែរក្រហម

"មានជម្ងឺនៅខាងក្នុងបក្ស...យើងនាំគ្នារកមើលមេរោគ ដោយមិនបានទទួលជោគ ជ័យ.... ពួកវានឹងធ្វើឲ្យសង្គមពុករលួយ បក្សពុករលួយ

កងទ័ពពុករលួយ.... យើងត្រូវ តែប្រឈមជាមួយនឹងពួកវា ។"
– ប៉ុល ពត មេដឹកនាំខ្មែរក្រហម

កុំធ្វើពុតជាល្ងង់ ឬធ្វើពុតជាមិនយល់ ដោយសារអ្នកជាមនុស្សក្បត់នឹងបដិវត្ត ។
– បទបញ្ញត្តិសម្រាប់អ្នកទោសនៅមន្ទីរឃុំឃាំងស–21

ពេលគេសួរត្រូវឆ្លើយភ្លាម ។ ហាមដាច់ខាតមិនឲ្យពន្យារពេលឆ្លើយ ទោះបីជាមួយ វិនាទីក៏ដោយ ។
– បទបញ្ញត្តិសម្រាប់អ្នកទោសនៅមន្ទីរឃុំឃាំងស–21

ក្នុងពេលវាយ ឬធក់ខ្សែភ្លើង ហាមដាច់ខាតមិនឲ្យស្រែក ។
– បទបញ្ញត្តិសម្រាប់អ្នកទោសនៅមន្ទីរឃុំឃាំងស–21

ហាមដាច់ខាតមិនឲ្យធ្វើសកម្មភាពអ្វីឡើយ ។ អង្គុយស្ងៀម រង់ចាំបញ្ជារបស់ខ្ញុំ ។ បើគ្មានបញ្ជារបស់ខ្ញុំទេ ហាមធ្វើអ្វីទាំងអស់ ។ ដាច់ខាតត្រូវធ្វើតាមគ្រប់យ៉ាងដែល ខ្ញុំបញ្ជាឲ្យធ្វើ ហាមបដិសេធការបញ្ជាណាមួយ ។
– បទបញ្ញត្តិសម្រាប់អ្នកទោសនៅមន្ទីរឃុំឃាំងស–21

បើអ្នកក្បត់នឹងបញ្ជាក្នុងចំណុចណាមួយរបស់ខ្ញុំ ត្រូវវាយ 10 ដំបង ឬធក់ខ្សែភ្លើង 5 ដង ។
– បទបញ្ញត្តិសម្រាប់អ្នកទោសនៅមន្ទីរឃុំឃាំងស–21

## ការបរាជ័យ និងការស្តីបន្ទោស

ប៉ុន្តែបដិវត្តមិនបានដើរដូចជាផែនការនោះឡើយ ។ កម្ពុជាប្រជាធិបតេយ្យ ដែលទើប តែផុសចេញពីសង្គ្រាមក្នុងស្រុកដ៏បំផ្លិចបំផ្លាញមួយ បានចាប់ផ្តើមផែនការបួនឆ្នាំរបស់ ខ្លួនចំពោះសមោហភាពវូបនីយកម្ម និងស្រែចម្ការ ជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធដែល រងនូវការខូចខាតយ៉ាងធំណាំ ។ កម្លាំងពលកម្មដែលខ្វះបទពិសោធន៍ និងទន់ជ្រាយ ជាមួយនឹងការិយាធិបតេយ្យដែលមិនមានប្រសិទ្ធិភាព បាននាំទៅរកកសិកម្មដែល មិនបានផលល្អ ធ្វើឲ្យប្រជាជនរាប់លាននាក់ត្រូវអត់ឃ្លាន ។

មន្ត្រីជាន់ខ្ពស់របស់ខ្មែរក្រហម បានជឿថា បក្សមិនដែលបានធ្វើខុសម្តងណាទេ ។ ជំនួសឲ្យការវាយតម្លៃឡើងវិញអំពីការគ្រប់គ្រង និងគោលនយោបាយរបស់ខ្មែរ ក្រហម ថ្នាក់ដឹកនាំបានស្តីបន្ទោសពីភាពបរាជ័យ លើពួកប្រឆាំងបដិវត្ត ខាងក្នុង និងខាងក្រៅ ។ ជាញយៗ ជនក្បត់ត្រូវបានចោទប្រកាន់ថាជាពួកប្រតិកិរិយារបស់ អំណាចបរទេស ដែលមានដូចជាភ្នាក់ងារសេអ៊ីអាអាមេរិក (CIA) ពួកកាហ្សេបេ (KGB) ឬពួកវៀតណាម ។ មន្ត្រីយោធា រដ្ឋការស៊ីវិល បញ្ញវ័ន្ត អ្នករស់នៅតាមទីក្រុង របស់របបចាស់ និងជនភាគតិច ដូចជាជនជាតិវៀតណាម ចិន និងចាម ជាក្រុមគោល ដៅដំបូង តែទីបញ្ចប់ ប្រជាជនកម្ពុជាគ្រប់រូប ត្រូវគេសង្ស័យថាជាសត្រូវរបស់ ប្រជា ជន ។ មេដឹកនាំខ្មែរក្រហមកាន់តែមានការសង្ស័យខ្លាំងឡើងៗ ហើយបាត់បង់ជំនឿ ជាមួយនឹងសមាជិកបក្សរបស់ខ្លួន ។

# មន្ទីរសន្តិសុខស-21

## ស-21 ៖ បន្ទប់រង់ចាំសេចក្តីស្លាប់

ពួកខ្មែរក្រហមបានបង្កើតនូវបណ្តាញដ៏ល្អិតល្អន់របស់គុកមួយ ដែលពួកគេសំដៅលើ មន្ទីរសន្តិសុខ ។ ប្រជាជនរាប់ពាន់នាក់ ត្រូវបានគេចាត់ទុកថាជាសត្រូវរបស់រដ្ឋ ត្រូវ ចាប់បញ្ជូនមកកាន់មន្ទីរសន្តិសុខ ដើម្បីឃុំឃាំង សួរចម្លើយ ធ្វើទារុណកម្ម និងកម្ទេច ចោល ។ ស–21 (ការិយាល័យសន្តិសុខ 21) គឺជាការិយាល័យដ៏ធំបំផុត និងជាកន្លែង ដែលសម្លាប់មនុស្សច្រើនបំផុត នៅក្នុងបណ្តាញនេះ ដែលមានកន្លែងបែបនេះចំនួន 196 ។ ពេលដែលស–21 បានស្ថិតក្នុងប្រតិបត្តិការពេញទំហឹង ក្នុងមួយដងមានអ្នក ទោសជាប់ឃុំពីរវាង 1000 ទៅ 1500 នាក់ ។ អ្នកទោសប្រុស ស្រី និងកុមារ ដែលមាន ចំនួនសរុប 14,000 នាក់ដែលត្រូវបានឃុំឃាំងនៅមន្ទីរស–21 ពីរវាងខែមិថុនា ឆ្នាំ1976 ដល់ខែមករា ឆ្នាំ1979 គឺមានអ្នកទោសតែ 23 នាក់ទេ ដែលក្នុងនោះមានកុមារ 5 នាក់ ផងបានចេញមក ដោយរួចជីវិត ។

ស–21 ជាគុកសម្ងាត់មួយ មានទីតាំងក្នុងអតីតវិទ្យាល័យមួយកន្លែង នៅជាយក្រុងភ្នំ ពេញ ។ ប្រធានគុកនេះគឺជាអតីតគ្រូបង្រៀនម្នាក់ ដែលមានឈ្មោះថា កាំង ហ្គិចអៀវ ដែលគេស្គាល់ថា ឌុច ហើយមានកងសន្តិសុខរាប់រយនាក់ ។ អ្នកទោសនៅមន្ទីរស–21 ភាគច្រើនជាសមាជិកបក្សខ្មែរក្រហម និងកងទ័ព (និងគ្រួសាររបស់ពួកគេ រួមទាំង កុមារ) ដែលរងការ ចោទប្រកាន់ថាជាជនក្បត់បដិវត្ត ។ ស្ទើរតែទាំងអស់នៃអ្នកជាប់ឃុំនៅមន្ទីរស–21 គឺជាមនុស្សសុច្ចរិត ចំពោះទោសកំហុសដ៏ធ្ងន់ធ្ងរ ដែលត្រូវគេ ចោទប្រកាន់ ។

## "កន្លែងដែលមនុស្សចូលទៅហើយមិនដែលឃើញចេញមកវិញឡើយ" *

* ជារហស្សនាមរបស់មន្ទីរស–21 ដែលកម្មករធ្វើការនៅរោងចក្រក្បែរខាងបានដាក់ឲ្យ ។

ក្នុងអំឡុងពេលជាប់គុក ដែលមានរយៈពេលពីច្រើនថ្ងៃ ដល់ច្រើនខែ អ្នកទោសត្រូវ បានគេសួរចម្លើយដដែលៗ ហើយអ្នកទោសភាគច្រើនត្រូវរងនូវទណ្ឌកម្មកម្រិតធ្ងន់ ឬរងការគម្រាមកំហែងដាក់ទណ្ឌកម្ម រហូតដល់ពួកគេសារភាពថាខ្លួនជាអ្នកប្រឆាំង នឹងបដិវត្ត ជាបទឧក្រិដ្ឋដែលគេបង្ខំឲ្យឆ្លើយថាខ្លួនបានប្រព្រឹត្ត ។ អ្នកទោសទាំងនោះ ក៏ត្រូវបានគេបង្ខំឲ្យប្រាប់ឈ្មោះ "ខ្សែ" នៃអ្នកសហការជាមួយខ្មាំង ឬ "ខ្សែបណ្តាញ អ្នកក្បត់" ។ អ្នកដែលមានឈ្មោះនៅក្នុងបញ្ជីប្រភេទនេះ គឺមានន័យថាអាចនឹងត្រូវ បានចាប់ខ្លួន ហើយដែលទីបំផុតនឹងត្រូវបញ្ជូនមកកាន់មន្ទីរស–21 ។ បន្ទាប់ពីការសួរ ចម្លើយ ត្រូវបាត់ទុកថាចប់ អ្នកទោសទាំងនោះ នឹងត្រូវបានដឹកទៅកាន់វាលពិឃាត ជើងឯកដែលនៅមិនឆ្ងាយពីទីនេះ ដែលពួកគេនឹងត្រូវបានកម្ទេចចោល ហើយកប់ ក្នុងរណ្តៅសពរួម ។

## រូបថត

រូបថតនៃអ្នកទោសមន្ទីរឃុំឃាំងស–21 ដែលអ្នកនឹងបានឃើញ នៅក្នុងបន្ទប់បន្ទាប់ ដើមឡើយត្រូវបានថតក្នុងគោលបំណងធ្វើអត្តសញ្ញាណកម្ម ។ រូបដែលមាន ទំហំប៉ុន រូបថតសម្រាប់ធ្វើលិខិតឆ្លងដែន ត្រូវបានដាក់ជាប់ទៅក្នុងឯកសាររបស់គុក ដែលមាន រួមទាំងជីវប្រវត្តិ និងចម្លើយសារភាព របស់អ្នកទោសដែលបានពីការបង្ខិតបង្ខំ ។ មន្ទីរ ស–21 គឺជាគុកតែមួយគត់ ដែលមើលការខុសត្រូវដោយខ្មែរក្រហម ដែលគេបានដឹង ថាបានរក្សាទុកកំណត់ត្រារូបថតជាច្រើន ។

អ្នកទោសនៅមន្ទីរឃុំឃាំងស–21 ត្រូវបានថតរូប ក្នុងពេលបញ្ជូនចូលមកក្នុងទីនេះ ។ ជាធម្មតា ពួកគេត្រូវបានបញ្ជូនមកទីនេះដោយមានកន្សែងបិទមុខ ចងប្រវ៉ាក់ ឬខ្សែពួរ ជាប់គ្នា ។ ជាធម្មតា លេខអត្តសញ្ញាណមួយ ត្រូវបានខ្ទាស់ជាប់នឹងស្បែករបស់ អ្នក ទោសម្នាក់ៗ ។ ភ្លាមៗបន្ទាប់ពីថតរូបរួច អ្នកទោសត្រូវបានគេបើកមុខ ។ ចំពោះអ្នក ទោសដែលស្លាប់ក្នុងពេលជាប់ឃុំ និងសមាជិកខ្មែរក្រហមដែលមានឋានៈខ្ពស់ ត្រូវបានកម្ទេចនៅឯមន្ទីរស–21 ក៏ត្រូវបានថតទុកដែរ ក្រោយពេលស្លាប់ ។ ដូស្ស "ដែល ពេញលេញ" ត្រូវបានដាក់ជូនទៅកាន់មេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្ហម ដើម្បីទុកជា "ភស្តុតាង" ថាជា "ខ្មាំង" ត្រូវបានកំចាត់ចោល ។

រូបថតរបស់អ្នកទោសនៅមន្ទីរឃុំឃាំងស–21 ដែលបានដាក់បង្ហាញនេះ គឺជាការផ្តិត ដោយប្រើទឹកប្រាក់ខាប់ ចេញពីហ្វិលដែលបានរកឃើញនៅឯមន្ទីរស–21 ។ រូបទាំង អស់ គឺជារូបដែលផ្តល់ដោយឥតគិតថ្លៃពីសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និង ក្រុមប័ណ្ណសាររូបថត ។

# តើពួកគេជានរណា?

ជាញយៗ គេតែងសួរថា តើអ្នកដែលមានរូបថតនៅឯមន្ទីរស–21 ពួកគេ ជានរណា? ដោយសារហ្វិល និងរូបថតដើម ដែលខ្មែរក្រហមជាអ្នកផលិត ត្រូវស្ថិតនៅបែកចេញ ពីឯកសារចម្លើយសារភាពរបស់អ្នកទោសមន្ទីរស–21 ក្នុងពេលភ្លាមៗដែលខ្មែរក្រហម បាត់បង់អំណាច ការកំណត់អត្តសញ្ញាណម្ចាស់រូបថត គឺជាការលំបាកមួយ ។ រូបថត មួយចំនួនធំស្ថិតក្នុងភាពអនាមិក ។

ការដឹងអ្វីមួយរបស់ជីវិត ដែលបានរលត់ទៅហើយក្នុងរបបខ្មែរក្រហម គឺជាសេច ក្តីព្រួយបារម្ភចម្បងរបស់ *ការធ្វើបុណ្យ និងពិធីរំឭកវិញ្ញាណខ័ណ្ឌ* នេះ ។ ជាមួយនឹង ជំនួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា អត្តសញ្ញាណរបស់អ្នកទាំង 4 ត្រូវបានរក្សាទុក – ជាអំពើតស៊ូប្រឆាំងចំពោះអនាមិកភាពនៃការសម្លាប់រង្គាល ។

---

កន្លែងនេះ ត្រូវបានគ្រោងទុកសម្រាប់ធ្វើការឆ្លុះបញ្ចាំងដោយស្ងៀមស្ងាត់ ។ សំណង់ ដែលអ្នកឃើញ តំណាងឲ្យ*ចេតិយ* ម៉ូដសម័យ ដែលជាទ្រង់ទ្រាយរណ្តៅបញ្ចុះសព បបបូរាណ ឬសំណង់រំឭកចំពោះអ្នកស្លាប់របស់កម្ពុជា ។

សម្លេងថតដែលអ្នកបានស្តាប់ឮ គឺជាការសូត្របែបពុទ្ធសាសនាពីរបទ ដែលបានសូត្រ ដោយលោកតាព្រំ អ៊ិត កាលពីគាត់នៅរស់ (1945–2009) ។ ជាអ្នក ដែលមានដើម កំណើតនៅខេត្តកំពង់ស្ពឺ លោកតាព្រំ អ៊ិត ត្រូវបានអញ្ជើញមកកាន់ភ្នំពេញ ជាញឹក ញាប់ ដើម្បីសូត្រក្នុងពិធីបុណ្យសព និងពិធីសាសនា ផ្សេងៗ រួមទាំងពីធីបុណ្យមួយ ចំនួនដែលរៀបចំធ្វើនៅក្នុងសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ដើម្បីជាការរំឭក ដល់ជនរងគ្រោះក្នុងរបបខ្មែរក្រហម ។

ខ្សែអាត់ទីមួយ គឺជាសេចក្តីដកស្រង់នៃការសូត្ររបស់លោកតា ព្រំ អ៊ិត ជាភាសាបាលី ដែលមានឈ្មោះថា Sattappakaraṇābhidhamma ឬ "សេចក្តីសង្ខេបពីសៀវភៅទាំង ប្រាំពីរនៃការបង្រៀនជាន់ខ្ពស់" ជាបទសូត្រដែលធ្វើឡើងតំណាងឲ្យអ្នកស្លាប់ នៅឯ ពិធីបុណ្យតាមពុទ្ធសាសនាទូទាំង អាស៊ីអាគ្នេយ៍ ។ ខ្សែអាត់ទីពីរ គឺជាសេចក្តីដកស្រង់ ចេញពីការសូត្រតាមអត្ថបទជាភាសាខ្មែរ ក្នុងសៀវភៅ*ព្រះត្រៃលក្ខណ៍* ឬ "កំណត់ចំណាំទាំងបី" ។ ការសូត្រនេះត្រូវបានធ្វើឡើងសម្រាប់ជួយដល់អ្នកដែលជិតស្លាប់ និង ដើម្បីបញ្ជូនមគ្គផលរបស់អ្នកដែលជិតស្លាប់ ទៅដល់អ្នកដែលបានស្លាប់បាត់បង់ជីវិត ទៅហើយ ។

អត្ថបទសូត្រទីពីរ មានបកប្រែជាភាសាអង់គ្លេសខាងក្រោម ពន្យល់អំពី "ព្រះត្រៃលក្ខណ៍" ដែលមានឈ្មោះថា ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធប្រាប់យើងរាល់គ្នាថា យើងមិនអាចមានជីវិតរស់នៅជាអមតៈឡើយ (អនិច្ចំ) មិនអាចធ្វើឲ្យយើងពេញចិត្ត បានទាំងស្រុងឡើយ (ទុក្ខំ) ហើយទីបញ្ចប់មិនមែនជារបស់យើងដែរ (អនត្តា) ។

រូបំ ទុក្ខំ
ទុក្ខអើយទុក្ខខ្លាំង
ទុក្ខពន់ប្រមាណ
ពីតូចដល់ធំ
ទុក្ខក្នុងប្រាណ
ទុក្ខឥតស្រាកស្រាណ
ទុក្ខដល់ខ្លួនក្ស័យ ។

អនិច្ចំ ពុំឋិត
ពុំថេរនៅនិត្យ
យឺនយូរឡើយនៃ
ស្លាប់ទៅជាខ្មោច
អសោចពេកក្រៃ
ឆ្អឹងសាច់សរសៃ
ជាព្រះធរណី ។

អនត្តា សូន្យសោះ
សូន្យរូប សូន្យឈ្មោះ
សូន្យសព្វសញ្ញី
សូន្យយសសក្ខិតា
ធិការសោភី
សូន្យអស់ឥន្ទ្រីយ៍
មាសប្រាក់អន្តរាយ ។

ដូច្នេះបូរគិត
គួររក្សាចិត្ត
ខឹងឆាប់រសាយ
ចិត្តស្ងួនទន់ទោន
ដូចកូន និងម្តាយ
ខឹងឆាប់រសាយ
សូន្យបាត់ទៅហោង ។

# យើងខ្ញុំសូមអញ្ជើញលោកអ្នក បញ្ចេញនូវគំនិតរបស់ខ្លួន ....

សូមចំណាំថា សារមន្ទីរ អាចជ្រើសរើសសំណេរនៅក្នុងសៀវភៅនេះ ដើម្បីចែករំលែក ជាមួយសាធារណៈជន តាមរយៈវិបសាយ ។

*ចំពោះអ្នកដែលមានចិត្តស្ដីបន្ទោស និងសងសឹកជាមួយអ្នកដទៃ ចូរចងចាំថា ភាពស្អប់ ខ្ពើមមិនអាចបំបាត់គំនុំបានឡើយ ។ ចំពោះអ្នកដែលមិនមានចរិតស្ដីបន្ទោស និងសង សឹក ភាពស្អប់ខ្ពើម នឹងបាត់បង់អស់ពីខ្លួន ។ ភាពស្អប់ខ្ពើមមិនអាចរម្ងាប់ភាពស្អប់ ខ្ពើម បានឡើយ ។ ភាពស្អប់ខ្ពើមអាចរម្ងាប់បានដោយក្ដីស្រឡាញ់ ។ នេះជាច្បាប់អនន្តភាព ។*

*វាដូចគ្នាទៅនឹងអ្នកម្ដាយដែលពុះពារការពារកូនរបស់ខ្លួនមិនឲ្យមានគ្រោះថ្នាក់ បើទោះ បីជាត្រូវប្រថុយនឹងជីវិតរបស់ខ្លួនក៏ដោយ ដូច្នេះចូរយើងនាំគ្នាធ្វើឲ្យខ្លួនមានបេះដូង ស្អាតបរិសុទ្ធដោយគ្មានព្រំដែន ចំពោះសត្វមានជីវិតទាំងអស់ ។ ចូរយើងនាំគ្នាគិតអំពី ក្ដីស្រឡាញ់ ឲ្យបានជ្រួតជ្រាបទូទាំងពិភពលោក–ពិភពខាងលើ ពិភពខាងក្រោម និង ជុំវិញខ្លួនយើង ដោយមិនត្រូវឲ្យមានឧបសគ្គ មិនត្រូវឲ្យមានភាពស្អប់ខ្ពើម មិនត្រូវឲ្យមានភាពអមិត្ត មករារាំងបានឡើយ ។ ដរាបណាគ្រប់គ្នាដឹងខ្លួន ចូរយើងរក្សាសតិស្មារតី ឲ្យបានជាប់ជានិច្ច ។ នេះគឺដើម្បី បានទទួលពរសម្រាប់ជីវិតរស់នៅរបស់យើង ។*

– ពាក្យរបស់ព្រះពុទ្ធ ដកស្រង់ចេញពី*ព្រះសូត្រមេត្តា*

# អ្នកប្រព្រឹត្តបទឧក្រិដ្ឋ

ហាយនភាព និងអំពើប្រល័យពូជសាសន៍ ដែលបានកើតឡើងក្នុងប្រទេសកម្ពុជា និង ប្រទេសរវ៉ាន់ដា បង្ហាញថា ក្នុងកាលៈទេសៈដ៏ហួសហេតុមួយ មនុស្សធម្មតា អាចត្រូវ គេគ្រប់គ្រងឲ្យចូលរួមប្រព្រឹត្តអំពើប្រល័យពូជសាសន៍បាន ។ នៅប្រទេសកម្ពុជា សេចក្ដីប្រឹងប្រែងរបស់បដិវត្ត ធ្វើឲ្យអន្តរាយដល់បទដ្ឋានសង្គម ដាក់កំហិតលើ សីល ធម៌ និងការហាមឃាត់ផ្លូវច្បាប់ ។ ការបំផ្លែងសង្គមរ៉ាឌីកាល់នេះ បានកើតឡើងក្នុង អំឡុងពេលបន្ទាប់ពីមានភាពចលាចលខ្លាំងនៃសេដ្ឋកិច្ចសង្គមក្រោយសង្គ្រាម វៀត ណាម ការទម្លាក់គ្រាប់បែកដ៏ខ្លាំងក្លានៅក្នុងប្រទេសកម្ពុជា រដ្ឋប្រហារប្រឆាំងព្រះអង្គម្ចាស់សីហនុ និងសង្គ្រាមក្នុងស្រុកដែលអូសបន្លាយ ។

អ្នកគ្រប់គ្រង និងអ្នកសួរចម្លើយជាន់ខ្ពស់នៅឯមន្ទីរស–21 ដូចជា ឌុច និងម៉ម ណៃ ដែលជាប្រធានក្រុមអ្នកសួរចម្លើយ កាលពីមុនពួកគេសុទ្ធតែជាមនុស្សធម្មតា – ភាគ ច្រើនជាមនុស្សស្ថិតក្នុងវ័យសាមសិបផ្លាយឆ្នាំ ដែលធ្លាប់ធ្វើជាគ្រូបង្រៀន ។ ភាគច្រើន នៃកម្មករធ្វើការនៅក្នុងមន្ទីរស–21 សុទ្ធតែជាបុរសក្មេងៗមកពីជនបទ ដែលធ្លាប់ជា សិស្សបឋមសិក្សា បួសជាលោកណេន ឬជាអ្នកជួយធ្វើការតាមកសិដ្ឋានជាលក្ខណៈ គ្រួសារ ។

ក្នុងភាពរួមគ្នាជាមួយនឹងអ្នកប្រព្រឹត្តិអំពើប្រល័យពូជសាសន៍ដទៃទៀត កម្មករនៅក្នុង មន្ទីរស–21 សុទ្ធតែបាននិយាយថា ពួកគេគឺគ្រាន់តែ "ធ្វើតាមបញ្ជា" តែប៉ុណ្ណោះ – ការ ចូលរួមធ្វើទារុណ្ណកម្ម និងការសម្លាប់ គឺជាការស្ដាប់បញ្ជាជាមូលដ្ឋានរបស់ "អង្គការ" (អ្នកដឹកនាំបដិវត្ត) ហើយពួកគេខ្លាចត្រូវស្ដីបន្ទោស ប្រសិនជាពួកគេបដិសេធធ្វើតាម បទបញ្ជាដែលបានទទួល ។ ឡោ ដែលជាឆ្មាំគុកស–21 ហើយបានក្លាយជាអ្នកកម្ទេចបាននិយាយថា ៖ "ខ្ញុំត្រូវតែស្ដាប់បញ្ជាថ្នាក់លើរបស់ខ្ញុំ ។ បើគេបញ្ជាឲ្យធ្វើអ្វី ខ្ញុំត្រូវតែធ្វើ ។ បើយើងមិនស្ដាប់បញ្ជាទេ គេនឹងសម្លាប់យើងចោល" ។ ភាពត្រូវគ្នា ការគាបសង្កត់ ពីមិត្តភ័ក្តិ និងភាពជាវិជ្ជាជីវៈ គឺជាកត្តាលើកទឹកចិត្តបន្ថែមទៀត ។

កម្មករស–21 ដែលបានចូលរួមធ្វើទណ្ឌកម្ម និងកម្ទេចអ្នកទោស ជាធម្មតា គឺត្រូវបានធ្វើ ឲ្យស៊ាំនឹងបរិយាកាស ដើម្បីធ្វើកិច្ចការដែលកាន់តែសាហាវ ពេលដែលពួកគេកាន់តែ លែងមានវិញ្ញាណទុក្ខសោកចំពោះអំពើឃោរឃៅ ។ ពួកគេជាមនុស្សដែលបានទទួល ការបញ្ចុះបញ្ចូល ឲ្យជឿថាពួកគេបម្រើ "អង្គការ" ដោយការលុបបំបាត់នូវភាពមិនសុទ្ធ ដែលជាសមាសធាតុជម្ងឺរបស់សង្គម ព្រមទាំង "សត្រូវលាក់មុខដែលស៊ីរូងខាងក្នុង" – ដែលពួកគេទាំងនោះ គឺជាអ្នកដែលបង្កនូវគ្រោះថ្នាក់ចំពោះសង្គមបដិវត្តថ្មី ។ អ្នក ទោសមន្ទីរស–21 ត្រូវបានអ្នកប្រព្រឹត្តបទឧក្រិដ្ឋមើលឃើញថាជាកាកសំណល់មនុស្ស ហើយជាក្រុមគោលដៅដែលត្រូវកម្ទេចចោល ដែលទារុណកម្ម និងការកម្ទេចរបស់ ពួកគេ មិនមានអ្វីពាក់ព័ន្ធនឹងបញ្ហាសីលធម៌ឡើយ ។

# អ្នកថតរូប

រូបថតរបស់អ្នកទោសមន្ទីរស–21 ដែលបានដាក់បង្ហាញក្នុងពិពណ៌នេះ ត្រូវបានថត ដោយ ញ៉ែម អែន និងបុគ្គលិកជំនួយការចំនួន 5 នាក់ ដែលជាអនុក្រុមរៀបចំឯកសារ នៅមន្ទីរស–21 ។ អែន បានចូលរួមជាមួយខ្មែរក្រហមពេលដែលខ្លួនមានអាយុ 10 ឆ្នាំ ។ ប្រាំឆ្នាំក្រោយមក គេបានបញ្ជូនលោកទៅប្រទេសចិន ដើម្បីរៀនថតរូប ។ ពេល គាត់ត្រឡប់មកកម្ពុជាវិញ គឺពេលដែលគាត់មានអាយុ 16 ឆ្នាំ គាត់ត្រូវបានគេឲ្យធ្វើជា ប្រធាន អ្នកថតរូបនៅឯមន្ទីរស–21 ។ អែន បានថតរូប និងទទួលខុសត្រូវការរៀបចំ ឯកសាររូបភាព នៃអ្នកទោស ដែលមានចំនួនច្រើនជាង 14,000 នាក់ ដែលត្រូវបញ្ជូន មកតាមរយៈមន្ទីរស–21 ។

ញ៉ែម អែន បានរស់នៅជាមួយក្រុមខ្មែរក្រហមរហូតដល់ឆ្នាំ 1996 ដែលពេលនោះ គាត់បានរត់ចោលជួរ ក្រោមការលើកលែងទោស របស់រដ្ឋាភិបាល ។ ក្នុងឆ្នាំ 2007 គាត់បានបង្ហាញខ្លួនក្នុងនាមជាសាក្សី នៅមុខតុលាការ ឧក្រិដ្ឋកម្មខ្មែរក្រហមរបស់ កម្ពុជា ពេលដែល សភាជាបុរសបានរៀបចំសំណុំរឿងប្រឆាំងនឹងអតីតប្រធានមន្ទីរស–21 កាំង ហ្កិចអៀវ ។ នាពេលបច្ចុប្បន្ន អែន បានបម្រើការជាអភិបាលរងរបស់ស្រុកអន្លង់វែង ។

# ការដួលរលំនៃរបបខ្មែរក្រហម

នៅចុងឆ្នាំ 1978 កងទ័ពវៀតណាម និងកងកម្លាំងសម្ព័ន្ធមិត្តកម្ពុជាប្រឆាំងខ្មែរ ក្រហមរបស់ខ្លួន បានវាយចូលប្រទេសកម្ពុជា ដែលជាការឆ្លើយតបចំពោះការវាយ ចូលប្រទេសវៀតណាមរបស់ខ្មែរក្រហម ។

កងទ័ពវៀតណាម បានកាន់កាប់ក្រុងភ្នំពេញនីថ្ងៃទី7 ខែមករា ឆ្នាំ1979 ហើយបាន លើកបន្តុបរដ្ឋាភិបាលកុម្មុយនិស្តថ្មី ដែលមានឈ្មោះថា សាធារណៈរដ្ឋប្រជាមានិត្រ កម្ពុជា ។ ខ្មែរក្រហម បានស្ថិតនៅជាចលនាអ្នកបះបោរ តាមតំបន់មួយចំនួន របស់ ប្រទេស រហូតដល់ចុងឆ្នាំ 1990 ហើយបានលោយខ្លួនយ៉ាងពេញលេញ បន្ទាប់ពីការ ស្លាប់របស់ប៉ុល ពត ក្នុងឆ្នាំ 1998 ។ បើទោះបីជាមានភស្តុតាងអំពីអំពើព្រៃផ្សៃ ដែលបានកើតឡើង នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏ប្រទេសមហាអំណាច ពិភពលោក មានរួមទាំងសហរដ្ឋអាមេរិក និងប្រទេសចិន បានបន្តការគាំទ្ររបស់ខ្លួន មកលើពួកខ្មែរក្រហម ។ ការពិតពួកខ្មែរក្រហមជាអ្នកកាន់កាប់ កៅអីរបស់កម្ពុជា នៅអង្គការសហប្រជាជាតិ រហូតដល់ឆ្នាំ 1992 ។ សន្និបាទទីក្រុងប៉ារីស នាឆ្នាំ1991 អំពីកម្ពុជា បង្កើតបាននូវកិច្ចព្រមព្រៀង មួយដែលមានការធានាពីអន្តរជាតិ ដោយមានគោលបំណងនាំសន្តិភាព ត្រឡប់មកកាន់ប្រទេសវិញ ។ ការបោះឆ្នោតជាតិលើក ទីមួយ ដែលរៀបចំដោយអាជ្ញាធរអន្តរកាលរបស់អង្គការសហប្រជាជាតិប្រចាំកម្ពុជា (UNTAC) នៅខែឧសភា ឆ្នាំ1993 ។

# ការងើបឡើង និងការដួលរលំរបស់ខ្មែរក្រហម

**ទសវត្សរ៍ 1940** ៖ ចលនាកុម្មុយនិស្តកម្ពុជា បានលេចមុខឡើង ចេញពីការតស៊ូរបស់ ប្រទេសប្រឆាំងនឹងអាណានិគមបារាំង ។

**ទសវត្សរ៍ 1960** ៖ ព្រះបាទនពោត្តម សីហនុ បានដាក់ឈ្មោះឲ្យក្រុមកុម្មុយនិស្តប្រឆាំង ជាមួយនឹងទ្រង់ថា "ខ្មែរក្រហម" ។ ឈ្មោះជាផ្លូវការរបស់ពួកគេគឺ បក្សកុម្មុយនិស្ត កម្ពុជា (CPK) ។

**ឆ្នាំ 1963** ៖ ប៉ុល ពត បានក្លាយជាអគ្គលេខាធិការរបស់បក្ស និងជាអ្នកដឹកនាំ CPK ។

**ខែមីនា ឆ្នាំ1970** ៖ សង្គ្រាមក្នុងស្រុកកម្ពុជាបានចាប់ផ្តើម ។ សេនាប្រមុខ លន់ ណុល និងក្រុមគាំទ្រអាមេរិកាំងរបស់គាត់

បានធ្វើរដ្ឋប្រហារប្រកបដោយជោគជ័យ ដើម្បី ទម្លាក់ព្រះអង្គម្ចាស់សីហនុ ចេញពីឋានៈ ជាប្រមុខរដ្ឋ ។

**ឆ្នាំ1973** ៖ ពួកខ្មែរក្រហមបានក្លាយជាតួអង្គដ៏សំខាន់ នៅក្នុងសង្គ្រាមក្នុងស្រុក ហើយ បានចំណេញសមាជិកថ្មីជាច្រើន ដោយសារថា មនុស្សជាច្រើន មានគំនិតប្រឆាំងនឹង លន់ ណុល និងការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ។ នៅពេលនោះ 85 ភាគ រយនៃដែនដីរបស់កម្ពុជា ត្រូវបានគ្រប់គ្រងដោយពួកខ្មែរក្រហម ។

**ថ្ងៃទី17 ខែមេសា ឆ្នាំ1975** ៖ ពួកខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងភ្នំពេញទាំងស្រុង ។ ពីរបីថ្ងៃក្រោយមក ពួកគេបានបង្ខំឲ្យមនុស្សរស់នៅក្នុងក្រុងភ្នំពេញ ដែលមានចំនួន ប្រហែលជាពីរលាននាក់ ចាកចេញពីទីក្រុងភ្នំពេញ និងទីក្រុងដទៃទៀត ទៅកាន់ទី ជនបទ ដើម្បីធ្វើការងារកសិកម្ម ។ ក្នុងពេលជន្លាសចេញ មានមនុស្សរាប់ ពាន់នាក់ បានស្លាប់បាត់បង់ជីវិត ។ ដោយសារតែរឿងនេះ និងគោលនយោបាយដទៃទៀត មានមនុស្សស្ទើរតែពីរលាននាក់បានបាត់បង់ជីវិត ក្នុងអំឡុងរបបខ្មែរក្រហម ពីឆ្នាំ1975 ដល់ឆ្នាំ1979 ។

**ថ្ងៃទី30 ខែមេសា ឆ្នាំ1975** ៖ ការរលំរបស់ទីក្រុងព្រៃនគរ ដែលជារដ្ឋធានីរបស់ប្រទេស វៀតណាមខាងត្បូង ដោយសារកងកម្លាំងរបស់វៀតណាមខាងជើង ។ ប្រទេសវៀត ណាមដែលបែកចេញជាពីរចំណែក ក៏បានរួបរួម គ្នាវិញក្រោមរដ្ឋាភិបាលកុម្មុយនិស្ត ។

**ឆ្នាំ1976** ៖ CPK បានបង្កើតរដ្ឋកម្ពុជាប្រជាធិបតេយ្យ ហើយបានរៀបចំផែន ការបួនឆ្នាំ ដែលត្រូវបានគេហៅថា ការធ្វើសមោហភាវូបនីយកម្មនៃទ្រព្យសម្បត្តិឯកជនទាំងអស់ ហើយផ្តល់អាទិភាពខ្ពស់របស់ជាតិលើការដាំស្រូវ ។ គ្រួសាររបស់កម្ពុជាត្រូវបាន បំបែកចេញពីគ្នា ហើយប្រជាជនត្រូវបានគេ រៀបចំឲ្យធ្វើការជាក្រុម ។ គោលបំណង របស់ផែនការបួនឆ្នាំ គឺធ្វើយ៉ាងណាឲ្យអាចសម្រេចបាននូវទិន្នផលស្រូវជាមធ្យម ចំនួនបីតោនក្នុងមួយហិចតា នៅទូទាំងប្រទេស ។ ដើម្បីអាចសម្រេចគោលបំណងនេះបាន ប្រជាជនកម្ពុជាមួយភាគធំ ត្រូវបានបង្ខំឲ្យធ្វើស្រែ ចំនួនច្រើនជាង 12 ម៉ោងក្នុងមួយថ្ងៃ ពេញមួយឆ្នាំ ដោយមិនមានការសម្រាក និងអាហារគ្រប់គ្រាន់សម្រាប់បរិភោគឡើយ ។

**ចុងឆ្នាំ1977** ៖ ជម្លោះប្រដាប់អាវុធ បានផ្ទុះឡើងរវាងកម្ពុជា និងវៀតណាម ។ មនុស្ស រាប់ម៉ឺននាក់ ត្រូវបានគេបញ្ជូនទៅច្បាំង ហើយរាប់ពាន់នាក់បានស្លាប់បាត់បង់ជីវិត ។

**ខែធ្នូ ឆ្នាំ**1978 ៖ ទាហានវៀតណាម និងកងកម្លាំងរបស់រណសិរ្សសាមគ្គី សង្គ្រោះជាតិ របស់កម្ពុជា បានច្បាំងចូលមកក្នុងកម្ពុជា ។

**ថ្ងៃទី7 ខែមករា ឆ្នាំ1979** ៖ កងទ័ពវៀតណាម បានវាយកាន់កាប់ទីក្រុងភ្នំពេញ ។ ពួកមេ ដឹកនាំខ្មែរក្រហម បានរត់គៀសខ្លួនទៅកាន់ទិសខាងលិច ហើយបានរៀបចំបង្កើតកង កម្លាំងរបស់ខ្លួនឡើងវិញនៅក្នុងប្រទេសថៃឡង់ដ៍ ។

រហូតដល់ឆ្នាំ1992 អង្គការសហប្រជាជាតិ នៅតែបានបន្តទទួលស្គាល់ខ្មែរក្រហមថាជា តំណាងស្របច្បាប់តែមួយគត់របស់កម្ពុជា ។

**ឆ្នាំ1982** ៖ ខ្មែរក្រហម និងភាគីដទៃទៀតបានរួមគ្នាបង្កើតរដ្ឋាភិបាលចម្រុះត្រីភាគី ។ ក្នុងពេលជាមួយគ្នា នៅឯទីក្រុងភ្នំពេញ វៀតណាមបានជួយបង្កើតរបបរដ្ឋាភិបាល ថ្មីមួយ ដែលហៅថា សាធារណរដ្ឋប្រជាមានិត្យកម្ពុជា (PRK) ដែលបានគ្រប់គ្រងប្រទេសកម្ពុជា អស់ពេលមួយទសវត្សរ៍ ។

**ឆ្នាំ1990** ៖ កងទ័ពវៀតណាម បានដកថយពីកម្ពុជា ។

**ថ្ងៃទី23 ខែតុលា ឆ្នាំ1991** ៖ គ្រប់ភាគីរបស់កម្ពុជាទាំងអស់ បានចុះហត្ថលេខាកិច្ចព្រម ព្រៀងសន្តិភាពមួយ នៅទីក្រុងប៉ារីស ហើយបានយល់ព្រមរៀបចំការបោះឆ្នោតជាតិ ក្រោមការគ្រប់គ្រងរបស់អាជ្ញាធរអន្តរកាលរបស់ អង្គការសហប្រជាជាតិប្រចាំកម្ពុជា (UNTAC) ។ ពួកខ្មែរក្រហមបាន

ធ្វើពហិការមិនចូលរួមការបោះឆ្នោតដែលរៀបចំដោយ អង្គការសហប្រជាជាតិ ហើយបដិសេធរំលាយកងកម្លាំងរបស់ខ្លួន ។

**ឆ្នាំ1993** ៖ សភាជាតិដែលទើបតែបានជាប់ឆ្នោតថ្មីៗ បានបង្កើតច្បាប់រដ្ឋធម្មនុញ្ញប្រជា ធិបតេយ្យអាស្រ័យព្រះមហាក្សត្រ ដែលនាំឲ្យបង្កើតបាន ជារាជរដ្ឋាភិបាលកម្ពុជា ។ អស់រយៈពេលបីបួនឆ្នាំ កងកម្លាំងរបស់ខ្មែរក្រហម បាននៅបន្តការវាយប្រហារប្រឆាំង នឹងរដ្ឋថ្មី ។

**ឆ្នាំ1998** ៖ ប៉ុល ពត បានស្លាប់ ។ អ្នកដឹកនាំជាន់ខ្ពស់ដទៃទៀតរបស់ខ្មែរក្រហម បាន ចុះចូលជាមួយរដ្ឋាភិបាល ក្នុងឆ្នាំ1998 ។

**ខែមីនា ឆ្នាំ1999** ៖ អ្នកដឹកនាំខ្មែរក្រហមចុងក្រោយដែលនៅមានជីវិត ដែលបាន បដិសេធមិនចូលរួមជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា គឺ តាម៉ុក ត្រូវបានចាប់ខ្លួន ។

**ឆ្នាំ1999** ៖ ចលនាខ្មែរក្រហមបានដួលរលំ ។ អ្នកដឹកនាំទាំងអស់របស់ចលនានេះ បាន ចុះចូលជាមួយនឹងរាជរដ្ឋាភិបាល ត្រូវចាប់ខ្លួន ឬស្លាប់ ។

**ឆ្នាំ2008** ៖ អង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC) ត្រូវបានបង្កើតឡើងដោយ កម្ពុជា និងអង្គការសហប្រជាជាតិ ដើម្បីកាត់ទោស មេដឹកនាំ ជាន់ខ្ពស់របស់ខ្មែរក្រហម ដែលនៅមានជីវិត ។

**ខែកក្កដា ឆ្នាំ2010** ៖ ឌុច (កាំង ហ្កិចអៀវ) អតីតប្រធានមន្ទីរស–21 បានក្លាយជាមេដឹក នាំខ្មែរក្រហមទីមួយ ដែលបានរកឃើញកំហុសដោយ ECCC អំពីឧក្រិដ្ឋកម្មប្រឆាំង មនុស្សជាតិ និងប្រព្រឹត្តខុសយ៉ាងធ្ងន់ធ្ងរទៅនឹងសន្ធិសញ្ញាទីក្រុងហ្សឺណែវ ។

**ខែកុម្ភៈ ឆ្នាំ2012** ៖ អង្គតុលាការជាន់ខ្ពស់នៃ ECCC បានកាត់ទោសកាំង ហ្កិចអៀវ ដែលត្រូវបានគេស្គាល់ថា ឌុច អតីតប្រធានមន្ទីរស–21 ឲ្យជាប់គុកអស់មួយជីវិត ។

**ឆ្នាំ2012** ៖ ការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម 3 រូប កំពុងតែដំណើរការ ។

ប្រភព ៖ មួយភាគធំនៃបន្ទាត់ពេលវេលានេះ គឺអាស្រ័យលើកាលប្បវត្តិដែលបាន បោះពុម្ពផ្សាយអនឡាញ ដោយក្រុមត្រួតពិនិត្យសាលាក្តីកម្ពុជា តាមអាសយដ្ឋាន http://www.cambodiatribunal.org

# សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង

មិនយូរប៉ុន្មាន ក្រោយពេលដែលខ្មែរក្រហម ធ្លាក់ពីអំណាច ក្នុងខែមករា ឆ្នាំ1979 មន្ទីរ ស–21 ត្រូវបានបង្វែរទៅជាសារមន្ទីរមួយ ។ រូបថត របស់អ្នក ទោសរាប់ពាន់នាក់ ឧបករណ៍ធ្វើទណ្ឌកម្ម និងទីតាំងសារមន្ទីរនេះ ត្រូវបានដាក់បង្ហាញថាជាភស្តុតាងនៃ បទឧក្រិដ្ឋដែល ប្រព្រឹត្តដោយពួកខ្មែរក្រហម ។ ជនជាតិកម្ពុជាដែលនៅមានជីវិត បាន នាំគ្នាមកទស្សនាសារមន្ទីរ ហើយពិនិត្យមើលរូបថតអ្នកទោសដែល បានដាក់បង្ហាញ ដើម្បីស្វែងរកព័ត៌មានអំពីសាច់ញាតិ និងមិត្តភ័ក្តិរបស់ពួកគេដែលបានបាត់ដំណឹង ។ រហូតមកដល់សព្វថ្ងៃនេះ នៅឯសារមន្ទីរ ប្រល័យពូជសាសន៍ ទួលស្លែង រូតថតរបស់ អ្នកទោស បានបន្តស្ថិតនៅជាចំណុចកណ្តាលដ៏ សំខាន់នៃការតាំងពិពណ៌ជា អចិន្ត្រៃយ៍ របស់សារមន្ទីរ ។

# ការប្រមូលក្រុមបណ្ណសាររូបថត

ក្នុងឆ្នាំ1993 អ្នកសារព័ត៌មានអាមេរិកាំងពីររូបគឺ គ្រីស រីឡេ (Chris Riley) និងដឹក នីវិន (Doug Niven) បានលាតមើលហ្វិល ដែលមានរូបថតចំនួន 6,000 ដែលបានរក្សាទុក នៅក្នុងថតទូរឯកសារក្នុងការិយាល័យនៃសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ។ ដោយខ្វះការអភិរក្ស សូម្បីតែរបៀបថែរក្សាជាមូលដ្ឋាន ក៏គ្មានដែរ បានធ្វើឲ្យហ្វិលរូប ថតទាំងនោះ ត្រូវបានរងនូវការខូចខាតយ៉ាង លឿន ។ ដោយមើលឃើញពីសារៈ សំខាន់របស់រូបទាំងនោះ សម្រាប់ជាកំណត់ត្រាប្រវត្តិសាស្ត្រ និងភាពស្រងេះស្រងោច ចំពោះឥទ្ធិពលនៃរូបថតទាំងនោះ Riley និង Niven ត្រូវបានចូលរួមដោយ ជេហ្វ អាប៉ូតូលូ (Jeff Apostolou) ម៉ាខ ណ័រិស (Mark Norris) និងម៉ាយឃើល ផឹគិន ( Michael Perkins) ដើម្បីបង្កើតក្រុមបណ្ណសាររូបថត (Photo Archive Group) មួយឡើង ក្នុងរូបភាពជាអង្គការមិនរកកម្រៃ ដែលបានធ្វើការ ដើម្បីរក្សាឯកសាររូបថត ទាំងនេះរបស់មន្ទីរស–21 ។ ការប្រមូលហ្វិល រូបថតទាំងអស់ ដែលនៅសេសសល់ ត្រូវ បានយកមកលាងសំអាត និងដាក់ឈ្មោះ ដោយក្នុងនោះ រូបថតចំនួន 105 ដែលជ្រើស ចេញពីរូបដើមចំនួន 6,000 ត្រូវបានជ្រើសរើសសម្រាប់ផ្តិតធ្វើបណ្ណសារ ការបោះពុម្ព ផ្សាយ និងការតាំងពិពណ៌ ។ រូតថតអ្នកទោសមន្ទីរស–21 ដែលយកមក ដាក់បង្ហាញ ក្នុង*ពិធីបុណ្យ និងការរំឭកវិញ្ញាណខ័ណ្ឌអ្នកទោស* ត្រូវបានផ្តិតចេញពីហ្វិល ដែលបាន រកឃើញក្នុងសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ។

# ការរៀបរាប់របស់អ្នករស់រៀនមានជីវិត

**អ្នកមានជីវិតចេញពីមន្ទីរស–21 ៖ វ៉ាន់ ណាត**

វិចិត្រករគូរគំនូសម្រាប់លក់ លោកវ៉ាន់ ណាត (1946–2011) ត្រូវបានអង្គការបញ្ជូនឲ្យ ទៅធ្វើការនៅក្នុងកសិដ្ឋានសមោហភាពមួយ បន្ទាប់ពីខ្មែរក្រហមបានឡើងកាន់ អំណាចក្នុងឆ្នាំ 1975 ។ គាត់បានខំធ្វើការដោយស្តាប់បញ្ជាជានិច្ច តែនៅចុងឆ្នាំ1977 គេបានចាប់រូបគាត់ ដោយមូលហេតុអ្វីដែលអាជ្ញាធរមិនដែលបានប្រាប់គាត់ឲ្យដឹង ឡើយ ។ ក្រោយពីការសួរចម្លើយ និងការធ្វើទារុណកម្មរួចមក គេបានបញ្ជូនរូបគាត់ មកកាន់មន្ទីរស–21 ។ គាត់មានសំណាងបានរួចផុតជីវិត ដោយសារតែអ្នកដែលចាប់ គាត់បានរក ឃើញថា គាត់ចេះគូររូប ហើយពួកគេបានបញ្ជាឲ្យគាត់គូររូបប៉ុល ពត ។ បើគំនូររបស់គាត់មិនអាចធ្វើឲ្យមេដឹកនាំរីករាយទេ គាត់នឹងត្រូវស្លាប់ ។ សាច់រឿងចង ក្រងខាងក្រោម គឺជារឿងរបស់គាត់ ។

**អ្នករួចជីវិតពីរបបខ្មែរក្រហម ដែលឥឡូវនេះកំពុងរស់នៅប្រទេសកាណាដា**

ក្រោយពេលរួចផុតជីវិតពីរបបខ្មែរក្រហម ប្រជាជនកម្ពុជាជាច្រើននាក់បាននាំគ្នារត់ បោលស្រុកកំណើតដែលរងការបំផ្លិចបំផ្លាញរបស់ខ្លួន មកកាន់ជំរុំជនភៀសខ្លួន ជា ពិសេសជំរុំនៅក្នុងទឹកដីថៃ ដែលពួកគេអាចដាក់ពាក្យសុំទៅរស់នៅក្នុង ប្រទេសទីបី មួយចំនួន ដោយមានរួមទាំងប្រទេសកាណាដាផងដែរ ។ ប្រជាជនកម្ពុជាភាគច្រើន ដែលមករស់នៅក្នុងប្រទេស គឺបានមកដល់ក្នុងទស្សវត្សរ៍ឆ្នាំ1980 បន្ទាប់ពីនីតិបញ្ញត្តិ អន្តោប្រវេសន្តសហព័ន្ធ អនុញ្ញាតឲ្យជនភៀសខ្លួនមកពីប្រទេសអាស៊ីអគ្នេយ៍ អាចមក តាំងទីលំនៅក្នុងប្រទេសនេះបាន ។ មានជនភៀសខ្លួនកម្ពុជាចំនួនពីរម៉ឺននាក់ បានមក តាំងទីលំនៅក្នុងប្រទេសកាណាដា នៅក្នុងអំឡុងពេលនោះ ។ មួយភាគតូចនៃជន ភៀសខ្លួនទាំងនេះ ដែលជាអ្នកមានជីវិតរួចផុតពីរបបខ្មែរក្រហម បាននិយាយអំពីជីវិត របស់ពួកគេ នៅមុនពេល ក្នុងអំឡុងពេល និងក្រោយពេលរបបប្រល័យពូជសាសន៍ កម្ពុជា និងឆ្លុះបញ្ចាំងលើការរកឃើញនូវវិធានការណ៍មួយចំនួនសម្រាប់ផ្សះផ្សារ ជា មួយនឹងជំបៅរបស់ពួកគេកាលពីអតីតកាល ។

**យុត្តិធម៌ និងគណនេយ្យភាព**

សមាជិកជាន់ខ្ពស់បំផុតរបស់ខ្មែរក្រហមដែលនៅមានជីវិតរស់ ឥឡូវកំពុងតែឡើង តុលាការ កាត់ទោសពីបទឧក្រិដ្ឋដែលខ្លួនបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជាក្នុងអំឡុង ពេលពីរវាងថ្ងៃទី17 ខែមេសា ឆ្នាំ1975 និងថ្ងៃទី6 ខែមករា ឆ្នាំ1979 ។ ការចោទប្រកាន់ ប្រឆាំងនឹងពួកគេ រួមទាំងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC) ដែលត្រូវបានគេស្គាល់ជាទូទៅថាជាសាលាក្តីខ្មែរក្រហម ជាតុលាការកូនកាត់មួយ ដែល បានបង្កើតឡើងក្នុងឆ្នាំ2003 ដោយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ។ តុលាការនេះ ប្រើទាំងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ។ ការពន្យារពេលយូរមួយក្នុងការនាំ មេដឹកនាំខ្មែរក្រហមមកកាន់យុត្តិធម៌ គឺបណ្តាលមកពីអស្ថេរភាពនយោបាយ និងការ លូកដៃចូលរំខានក្នុងប្រទេសកម្ពុជា ផលប្រយោជន៍នយោបាយអន្តរជាតិដែលមាន ភាពសាំញ៉ាំ បញ្ហាប្រឈមចំពោះការបង្កើតសាលាក្តីក្នុងស្រុក ដោយមានការ ចូលរួមពី អន្តរជាតិ និងភាពខ្វះខាតមូលនិធិទ្រទ្រង់ ។

សំណុំរឿង 001 នៅឯ ECCC បានចាប់ផ្តើមនៅថ្ងៃទី30 ខែមីនា ឆ្នាំ2009 ។ កាំង ហ្គិចអៀវ ដែលមានឈ្មោះហៅក្រៅថា "ឌុច" ដែលជាប្រធានមន្ទីរឃុំឃាំងស-21 គឺជា ចុងចោទតែម្នាក់គត់ ។ គាត់ត្រូវបានតុលាការរកឃើញកំហុសថាបានប្រព្រឹត្តបទឧក្រិដ្ឋ ប្រឆាំងមនុស្សជាតិ និងការប្រឆាំងយ៉ាងខ្លាំងក្លាចំពោះសន្ធិសញ្ញាទីក្រុងហ្សឺណែវ ។ គាត់ត្រូវបានតុលាការកាត់ទោសឲ្យជាប់គុកអស់មួយជីវិត នៅថ្ងៃទី3 ខែកុម្ភៈ ឆ្នាំ2012 ។

សំណុំរឿង 002 បានចាប់ផ្តើមនៅថ្ងៃទី27 ខែមិថុនា ឆ្នាំ2011 ហើយពាក់ព័ន្ធនឹងអ្នក ដឹកនាំ ជាន់ខ្ពស់បំផុតរបស់ខ្មែរក្រហមចំនួនបីរូប ដែលនៅមានជីវិត ៖ នួន ជា "បងធំទី 2" អ្នកដឹកនាំក្នុងជួរកម្ពុជាប្រជាធិបតេយ្យដែលមានអំណាចខ្លាំងលំដាប់ទីពីរ បន្ទាប់ ពីប៉ុល ពត អៀង សារី អតីតឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេស ព្រមទាំង ខៀវ សំផន អតីតប្រធានក្រុមប្រឹក្សារដ្ឋ ។ ពួកគេបានបដិសេធមិនព្រមនិយាយ អំពីតួនាទីរបស់ពួកគេក្នុងរបបខ្មែរក្រហម ឬទទួលខុសត្រូវលើបទឧក្រិដ្ឋណាមួយឡើយ ។

ខណៈពេលដែលមានការសង្ឃឹមយ៉ាងខ្ពស់ថា ការកាត់ក្តី និងការកាត់ទោសក្នុងសំណុំ រឿង 002 នឹងអាចផ្តល់ជូននូវវិធានការណ៍យុត្តិធម៌សម្រាប់ជនរងគ្រោះពីរបបខ្មែរ ក្រហម ប្រជាជនកម្ពុជាមានទស្សនៈចម្រុះគ្នាអំពីលទ្ធផលក្តីនេះ ។ ខណៈពេលដែល គ្រួសារមួយចំនួនរបស់ជនរងគ្រោះមានអារម្មណ៍ធូរស្រាលក្នុងដាក់ទណ្ឌកម្មអ្នក ប្រព្រឹត្តបទឧក្រិដ្ឋកម្ម គ្រួសារដទៃទៀតជឿក្នុងផ្លូវពុទ្ធសាសនា (ការលើកលែងទោស) ដើម្បីបញ្ចប់វដ្តនៃអំពើហិង្សា ។ ការកាត់ក្តីត្រូវមានដំណើរការយ៉ាងយឺត ដោយការលា ឈប់របស់ចៅក្រមមួយចំនួន ការព្រួយបារម្ភអំពីឥស្សរភាពរបស់តុលាការ និងការជ្រៀត ជ្រែកពីរដ្ឋាភិបាលកម្ពុជា ក្នុងដំណើរការកាត់ក្តី ។ យើងនៅមិនទាន់ដឹងទេថា តើ ECCC នឹងបន្តកាត់ក្តីសំណុំរឿងបន្ថែមទៀតដែរឬទេ ។

# និយមន័យអំពីការចោទប្រកាន់

និយមន័យទាំងនេះ គឺសំអាងលើនិយមន័យទាំងឡាយដែលសាលាក្តីខ្មែរក្រហម កំពុង ប្រើក្នុងការកាត់ក្តីបច្ចុប្បន្ន ប្រឆាំងនឹងមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមបីរូប ។

# ប្រល័យពូជសាសន៍

អំពើប្រល័យពូជសាសន៍ ត្រូវបានប្រព្រឹត្តដោយមានចេតនាដើម្បីបំផ្លាញ មនុស្សជាតិ ជនភាគតិច ជាតិសាសន៍ ឬក្រុមអ្នកកាន់សាសនា ចោលទាំងស្រុង ឬមួយផ្នែក ។ យោងតាមសន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីអំពីការការពារ និងការដាក់ទណ្ឌ កម្មចំពោះបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ទង្វើទាំងនេះអាចរួមបញ្ចូលនូវ ៖ ការកាប់ សម្លាប់ ធ្វើឲ្យគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរចំពោះផ្លូវកាយ និងផ្លូវចិត្ត បង្កើតឲ្យមានវិបត្តិ ផ្សេងៗដូចជា ភាពអត់ឃ្លាន ដែលនាំទៅរកការបំផ្លាញរាងកាយរបស់ក្រុមមនុស្ស ការ ពារមិនឲ្យមានកំណើតទារក ឬការផ្ទេរកុមារដោយបង្ខំពីក្រុមមួយទៅក្រុមមួយទៀត ។ បទឧក្រិដ្ឋភាគច្រើនដែលបានប្រព្រឹត្តដោយខ្មែរក្រហម មិនអាចចោទប្រកាន់ថាជា អំពើប្រល័យពូជសាសន៍បានឡើយពីព្រោះថាពួកគេបានប្រព្រឹត្តប្រឆាំងនឹងមនុស្ស ដោយមូលហេតុនយោបាយ ។ ដូច្នេះ ការចោទប្រកាន់ពីបទប្រល័យពូជសាសន៍ គឺ មានដែនកំណត់ចំពោះការប្រព្រឹត្តមកលើក្រុមជនភាគតិចវៀតណាម និងចាម ។

# ឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ

"ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ជាអំពើដែលបានប្រព្រឹត្តឡើងជាផ្នែកមួយនៃការ រីករាលដាល ឬការវាយប្រហារជាប្រព័ន្ធ ដែលសំដៅលើប្រជាជនស៊ីវិល ដែលខ្លួន បានដឹងពីការវាយប្រហារនេះ ។ មូលហេតុអំពីការវាយប្រហារ ត្រូវតែជាប្រជាជន ស៊ីវិល ទស្សនៈនយោបាយ ក្រុមជនជាតិភាគតិច ពូជសាសន៍ ឬសាសនា ។ ឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិរួមបញ្ចូលនូវឃាតកម្ម ការកម្ទេចចោល ការបង្ខំឲ្យធ្វើជាទាសករ ការដាក់គុកក្នុងបទរំលោភច្បាប់ ផ្ទៃក្នុង ទណ្ឌកម្ម ការបណ្ដេញ ឬការផ្ទេរប្រជាជន ចេញដោយបង្ខំ និងការរំលោភ ។

# ឧក្រិដ្ឋកម្មសង្គ្រាម ៖ ការប្រព្រឹត្តិខុសយ៉ាងធ្ងន់ធ្ងរប្រឆាំងនឹងសន្ធិសញ្ញាទីក្រុងហ្សឺណែវ

ឧក្រិដ្ឋកម្មសង្គ្រាម គឺជាការប្រព្រឹត្តិរំលោភយ៉ាងធ្ងន់ធ្ងរ ចំពោះច្បាប់ និងទម្លាប់ ដែល ប្រើក្នុងជម្លោះប្រដាប់អាវុធជាលក្ខណៈអន្តរជាតិ ឬមិនអន្តរជាតិ ។ ឧក្រិដ្ឋកម្មសង្គ្រាម រួមបញ្ចូលនូវការសម្លាប់ដោយចេតនា ការធ្វើទណ្ឌកម្ម ឬការប្រព្រឹត្តិអមនុស្សចំពោះ សត្រូវជាអ្នកប្រយុទ្ធ អ្នកទោសសង្គ្រាម និងជនស៊ីវិល ការបង្កឲ្យមានទុក្ខ ឬរបួស ធ្ងន់ធ្ងរដោយចេតនា បង្ខំឲ្យនរណាម្នាក់ចូលបម្រើកម្លាំងប្រដាប់អាវុធ ការបដិសេធមិន ឲ្យមានការកាត់ទោសរកយុត្តិធម៌ ការបំផ្លិចបំផ្លាញ ឬការបង្ករការខូចខាតធ្ងន់ធ្ងរចំពោះ ទ្រព្យសម្បត្តិដែលស្ថិតនៅក្រៅភាពចាំបាច់ខាងផ្នែកយោធា និងការបណ្ដេញចេញពី ប្រទេស ការផ្ទេរ ឬការឃុំឃាំងមនុស្សដោយខុសច្បាប់ ។

### ការការពារអំពើប្រល័យពូជសាសន៍ ៖ តើយើងអាចធ្វើអ្វីបាន?

សេចក្ដីថ្លៃថ្នូរបស់ជនរងគ្រោះក្នុងរូបថត ដែលបានដាក់បង្ហាញក្នុងការ តាំងពិពណ៌នេះ មានភាពផ្ទុយគ្នាស្រឡះពីអ្វីដែលជាបំណងដើមរបស់រូបថតទាំងនេះ – កំណត់ត្រា ការិយាធិបតេយ្យនៃមនុស្សដែលគេបានផ្ដន្ទាទោសរហូតដល់ស្លាប់ ។

រូបថតអ្នកទោសមន្ទីរស–21 ក្រើនរំឭកយើងអំពីបរាជ័យរបស់ពិភពលោកក្នុងការ ការពារមនុស្សជាតិពីអំពើព្រៃផ្សៃយង់ឃ្នង តាមកន្លែងជាច្រើន (កម្ពុជា បូស្នី រ្វ៉ាន់ដា ដាហ្វួរ ...) ។ បើទោះបីជារូបថតទាំងនេះ បង្កើតបានជាឯកសារប្រល័យពូជសាសន៍ កាលពីអតីតកាលក៏ដោយ ក៏វាសនារបស់អ្នកទាំងនេះ ជម្រុញឲ្យយើងមានចិត្តចង់ការ ពារអំពើព្រៃផ្សៃយង់ឃ្នងមិនឲ្យកើតឡើងនាពេលអនាគត ។

ROM សង្ឃឹមថា ការតាំងពិពណ៌នេះ នឹងបង្កើនការយល់ដឹង និងជម្រុញឲ្យសកម្មជន ជួយកសាងឆន្ទៈនយោបាយជាតិ និងអន្តរជាតិ ឲ្យហ៊ានប្រឈមជាមួយនឹងឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ ។ ចំណុចតូចមួយដែល យើងអាចធ្វើបានគឺ យើងគួរទាមទារឲ្យ តំណាងរបស់យើងដែលបានជាប់ឆ្នោត ដើរតួនាទីជាអ្នកដឹកនាំ ក្នុងការការពារអំពើ ប្រល័យពូជសាសន៍ និងអំពើព្រៃផ្សៃដទៃទៀត ជុំវិញពិភពលោក ។

សម្រាប់វិបសាយរបស់អង្គការដែលឧទ្ទិសខ្លួនក្នុងការប្រយុទ្ធប្រឆាំងនឹងការ រំលោភ សិទ្ធិមនុស្សជាលក្ខណៈអន្តរជាតិ សូមទស្សនាការតាំងពិពណ៌មីក្រូវិបសាយ នៅក្នុង វិបសាយរបស់ ROM តាមរយៈអាសយដ្ឋាន ៖ www.rom.on.ca/cambodia

ការតម្លើងមួយនេះ ដែលដើមឡើយបាន
ចងក្រងដោយកម្មវិធីប្រល័យពូជសាសន៍ កម្ពុជា នៅឯសកលវិទ្យាល័យយ៉េល បង្ហាញរូបគ្រប់គ្នានៃរូបថតដែលនៅ
សេសសល់ ទាំងអស់ច្រើនជាង 6,000 រូបនៃអ្នកទោសមន្ទីរស–21 ។ រូបថតរបស់អ្នកទោសមន្ទីរស–21 ចំនួន ~~8,000~~ ផ្សេងទៀត

(រាប់ឃើញថា មានចំនួនយ៉ាងហោចណាស់ 8,000) ដែល មិនមានជីវិតរស់នៅ ។
រយៈពេល ៖ 7 ម៉ោង

ការផ្តល់ជូនដោយឥតគិតថ្លៃរបស់ Ben Kiernan

# ធម៌សម្រាប់សន្តិភាព

*ការឈឺចាប់របស់ប្រជាជនកម្ពុជា មានភាពជ្រាលជ្រៅ ។*
*ពីការឈឺចាប់នេះ នាំឲ្យមានក្តីមេត្តាយ៉ាងធំធេង ។*
*ក្តីមេត្តាធំធេង ធ្វើឲ្យចិត្តមានសន្តិភាព ។*
*ចិត្តសន្តិភាព ធ្វើឲ្យមនុស្សសន្តិភាព ។*
*មនុស្សសន្តិភាព ធ្វើឲ្យសហគមន៍មានសន្តិភាព ។*
*សហគមន៍សន្តិភាព ធ្វើឲ្យប្រទេសមានសន្តិភាព ។*
*ហើយប្រទេសសន្តិភាព ធ្វើឲ្យពិភពលោកមានសន្តិភាព ។*
*សូមឲ្យមនុស្សជាតិទាំងអស់ រស់នៅប្រកបដោយសុភមង្គល និងសន្តិភាព ។*
*សាធុ ។*

– ព្រះមហាឃោសានន្ទ ព្រះសង្ឃពុទ្ធសាសនាកម្ពុជា (1929– 2007)